# (២៦)

# ប្រកាសស្តីពី

## វិធាន និងនីតិវិធីចំណាយសម្រាប់វគ្គបណ្តុះបណ្តាល និងសិក្ខាសាលានៃក្រសួង ស្ថាប័នថវិកាកម្មវិធី

លេខ: ៨៣៨ សហវ.ប្រក

ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ [illegible] សហវ.ប្រក

# ប្រកាស
## ស្តីពី
## វិធាននិងនីតិវិធីចំណាយ
## សម្រាប់មជ្ឈមណ្ឌលបណ្តុះបណ្តាលនិងសិក្ខាសាលា នៃក្រសួង ស្ថាប័នថវិកាកម្មវិធី

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងរបស់ ... រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល

- បានឃើញប្រកាសលេខ ២៣៧ សហវ.ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ៨៥៦ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការៀបចំនិងចាប់ផ្តើមអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ១៥៨៩ សហវ.ប្រក ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីរិធាននិងនីតិវិធីអនុវត្តប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសរបស់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយថវិកាតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយថវិកាតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណង លើកកម្ពស់ប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ តម្លាភាព គណនេយ្យភាព និងភាពទាន់ពេលនៃការអនុវត្តចំណាយសម្រាប់ការរៀបចំវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលា នៃក្រសួង ស្ថាប័នថវិកាកម្មវិធី។

**ប្រការ២.-**

ប្រកាសនេះ មានគោលដៅកំណត់អំពីវិធាននិងនីតិវិធីចំណាយសម្រាប់វគ្គបណ្តុះបណ្តាលនិងសិក្ខាសាលា នៃក្រសួង ស្ថាប័នថវិកាកម្មវិធី។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះក្រសួង ស្ថាប័នថវិកាកម្មវិធី ដែលអនុវត្តចំណាយលើការរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា។

**ប្រការ៤.-**

បច្ចេកសព្ទដែលត្រូវបានប្រើ ក្នុងក្របខ័ណ្ឌនៃប្រកាសនេះ ត្រូវបានកំណត់និយមន័យ ដូចខាងក្រោម៖

- ក្រសួង ស្ថាប័នថវិកាកម្មវិធី សំដៅដល់ក្រសួង ស្ថាប័នទាំងឡាយណា ដែលរាជរដ្ឋាភិបាល សម្រេចឱ្យអនុវត្តថវិកាកម្មវិធី។
- វគ្គបណ្តុះបណ្តាល សំដៅដល់សកម្មភាពនៃការផ្តល់ចំណេះដឹង ឬជំនាញជាក់លាក់ណាមួយ ក្នុងគោលដៅ

អភិវឌ្ឍសមត្ថភាព ដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងអ្នកចូលរួមពាក់ព័ន្ធផ្សេងទៀត ដើម្បីរួមចំណែកគាំទ្រដល់សមិទ្ធកម្មនៃគោលបំណងគោលនយោបាយ និងកម្មវិធីរបស់ក្រសួង ស្ថាប័ន។

- សិក្ខាសាលា សំដៅដល់សកម្មភាពនៃការផ្សព្វផ្សាយ ការពិគ្រោះយោបល់ ការណែនាំ ឬការផ្លាស់ប្តូរបទពិសោធន៍ ដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងអ្នកចូលរួមពាក់ព័ន្ធផ្សេងទៀត ដើម្បីបង្កើនប្រសិទ្ធភាព នៃការរៀបចំនិងការអនុវត្តគោលបំណងគោលនយោបាយ និងកម្មវិធីរបស់ក្រសួង ស្ថាប័ន។

## ជំពូកទី២

## ការកំណត់មុខសញ្ញាចំណាយ

**ប្រការ៥.-**

មុខសញ្ញាចំណាយសម្រាប់ការរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា រួមមាន÷

- ឯកសារនិងសម្ភារៈ មានជាអាទិ៍ ឯកសារឬសម្ភារៈដែលត្រូវថតចម្លងឬបោះពុម្ពជាលក្ខណៈបន្ទាប់បន្សំសម្រាប់គោលដៅនៃវគ្គបណ្តុះបណ្តាលឬសិក្ខាសាលា ខ្មៅដៃ ប៊ិក សៀវភៅសរសេរ ថង់ឬកាតាប សម្ភារៈពិសោធន៍ និងសម្ភារៈបច្ចេកទេសតូចតាច
- ការជួលទីតាំង ការរៀបចំទឹកន្លែង ការរៀបចំអាហារ និងការឧបត្ថម្ភអ្នកចូលរួម
- ការឧបត្ថម្ភគ្រូឧទ្ទេស
- ការឧបត្ថម្ភអ្នកសម្របសម្រួលនិងជំនួយការក្នុងវគ្គបណ្តុះបណ្តាលឬសិក្ខាសាលា
- ចំណាយផ្សេងៗ សម្រាប់បម្រើឱ្យសកម្មភាពបណ្តុះបណ្តាលនិងសិក្ខាសាលា។

**ប្រការ៦.-**

គោលការណ៍ចំណាយសម្រាប់ការរៀបចំវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលា ត្រូវកំណត់ផ្តល់ជូន ដូចខាងក្រោម÷

១- ចំណាយសម្រាប់ឯកសារ និងសម្ភារៈ ផ្តល់ជូនក្នុងកម្រិតមិនលើសពី ៤០ ០០០ (បួនម៉ឺន) រៀល/១នាក់/១វគ្គ។

២- ចំណាយលើការជួលទីតាំង ការរៀបចំទីកន្លែង ការរៀបចំអាហារ ការឧបត្ថម្ភអ្នកចូលរួម÷

- ក្នុងករណីប្រើប្រាស់ទីតាំងរបស់ក្រសួង ស្ថាប័ន ឬអង្គភាពរដ្ឋ ផ្តល់ជូនក្នុងកម្រិតមិនលើសពី ៤០ ០០០ (បួនម៉ឺន) រៀល/១នាក់/១ថ្ងៃ
- ក្នុងករណីត្រូវជួលទីតាំង ផ្តល់ជូនក្នុងកម្រិតមិនលើសពី ៦០ ០០០ (ប្រាំមួយម៉ឺន) រៀល/១នាក់/១ថ្ងៃ។

៣- ចំណាយឧបត្ថម្ភគ្រូឧទ្ទេស ផ្តល់ជូន ៨០ ០០០ (ប្រាំបីម៉ឺន) រៀល/១ម៉ោង សម្រាប់រយៈពេលកម្រិតអតិបរមាចំនួន ៨ ម៉ោង ក្នុងមួយថ្ងៃ។

៤- អ្នកសម្របសម្រួលនិងជំនួយការក្នុងវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលា ត្រូវបានកំណត់និងផ្តល់ប្រាក់ឧបត្ថម្ភជូន ដូចខាងក្រោម÷

ក. សម្រាប់ចំនួនអ្នកសម្របសម្រួលនិងជំនួយការ÷

- ផ្តល់ជូនអ្នកសម្របសម្រួល ១ នាក់ និងជំនួយការ ១ នាក់ សម្រាប់វគ្គបណ្តុះបណ្តាលឬសិក្ខាសាលា ដែលមានអ្នកចូលរួមតិចជាង ឬស្មើ ៣០ នាក់
- ចំនួនអ្នកសម្របសម្រួលនិងជំនួយការ អាចកើនទៅតាមសមាមាត្រ ដោយយកចំនួនអ្នកចូលរួមសរុប ចែកនឹងចំនួន ៣០ នាក់។ ក្នុងករណីមានសំណល់លើសពី ១០ ផ្តល់ជូនអ្នកសម្របសម្រួល

និងជំនួយការ ១ នាក់ បន្ថែមទៀត។

ខ. សម្រាប់ប្រាក់ឧបត្ថម្ភអ្នកសម្របសម្រួលនិងជំនួយការ÷

- អ្នកសម្របសម្រួល ផ្តល់ជូនចំនួន ៨០ ០០០ (ប្រាំបីម៉ឺន) រៀល/១នាក់/១ថ្ងៃ
- ជំនួយការ ផ្តល់ជូនចំនួន ៤០ ០០០ (បួនម៉ឺន) រៀល/១នាក់/១ថ្ងៃ។

៥- ចំណាយផ្សេងៗ ត្រូវផ្តល់ជូនក្នុងកម្រិតមិនលើសពី ៥ % នៃចំណាយសរុបខាងលើ។

ប្រការ៧.-

ក្នុងករណីចាំបាច់ ដែលមានតម្រូវការអនុវត្តចំណាយលើសពីគោលការណ៍ណាមួយ ដែលបានកំណត់ក្នុងប្រការ៦ នៃប្រកាសនេះ ក្រសួង ស្ថាប័នថវិកាកម្មវិធី ត្រូវស្នើសុំគោលការណ៍ដោយឡែក ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយ នូវការបញ្ជាក់អំពីមូលហេតុច្បាស់លាស់។

ប្រការ៨.-

ចំណាយបេសកកម្មដែលបម្រើឱ្យសកម្មភាពបណ្តុះបណ្តាលឬសិក្ខាសាលា ត្រូវអនុលោមតាមវិធាននិងនីតិវិធីជាធរមាន។

ប្រការ៩.-

ក្រសួង ស្ថាប័នថវិកាកម្មវិធី ត្រូវធ្វើវិចារណកម្មចំណាយ និងប្រកាន់ខ្ជាប់នូវការសន្សំសំចៃខ្ពស់ លើការរៀបចំវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលា ដោយកំណត់គោលដៅច្បាស់លាស់ ព្រមទាំងកំណត់សមាសភាពនិងកម្រិតចំនួននៃអ្នកចូលរួមឱ្យបានសមស្រប ត្រឹមត្រូវ និងជាក់លាក់ តាមសេចក្តីត្រូវការចាំបាច់ជាក់ស្តែង។

## ជំពូកទី៣

## វិធាននៃការគ្រោងឥណទានថវិកា

## សម្រាប់វគ្គបណ្តុះបណ្តាល និងសិក្ខាសាលា

ប្រការ១០.-

សម្រាប់វគ្គបណ្តុះបណ្តាល ឥណទានថវិកាតាមមុខសញ្ញាចំណាយដែលបានកំណត់ ត្រូវគ្រោងក្នុងជំពូក៦១ គណនី៦១០៤ "សោហ៊ុយបណ្តុះបណ្តាលបុគ្គលិកក្នុងនិងក្រៅប្រទេស"។

សម្រាប់សិក្ខាសាលា ឥណទានថវិកាតាមមុខសញ្ញាចំណាយដែលបានកំណត់ ត្រូវគ្រោងក្នុងជំពូក៦១ គណនី ៦១១០ អនុគណនី៦១១០៣ "ចំណាយសម្រាប់ប្រជុំ សិក្ខាសាលា សន្និសីទ"។

## ជំពូកទី៤

## នីតិវិធីអនុវត្តចំណាយសម្រាប់វគ្គបណ្តុះបណ្តាល និងសិក្ខាសាលា

ប្រការ១១.-

ឥណទានថវិកាសម្រាប់វគ្គបណ្តុះបណ្តាលនិងសិក្ខាសាលា ត្រូវបានអនុញ្ញាតឱ្យអនុវត្ត ១០០% តាមនីតិវិធីចំណាយនៃរដ្ឋទេយ្យប្បទាន។

ការអនុវត្តចំណាយសម្រាប់វគ្គបណ្តុះបណ្តាលនិងសិក្ខាសាលា ត្រូវអនុលោមតាមនីតិវិធីចំណាយថវិកាតាមរដ្ឋទេយ្យប្បទានជាធរមាន។

ប្រការ១២.-

ក្រសួង ស្ថាប័នថវិកាកម្មវិធី ត្រូវបោះផ្សាយអាណត្តិនិយ័តកម្ម ដោយភ្ជាប់នូវរបាយការណ៍ចំណាយ ដូចមានគំរូជាឧបសម្ព័ន្ធនៃប្រកាសនេះ ដោយរក្សាទុកសក្ខីបត្រដើម នៅអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ឬអង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិ ដែលត្រូវធ្វើជាកម្មវត្ថុនៃអធិការកិច្ច ឬសវនកម្មជាក្រោយ។ ក្នុងករណីចាំបាច់ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ឬអភិបាលហិរញ្ញវត្ថុ និងគណនេយ្យករសាធារណៈ មានសិទ្ធិស្នើសុំការបញ្ជាក់ឬការផ្តល់ឯកសារពាក់ព័ន្ធបន្ថែម។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

ប្រការ១៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ១៤.-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០១៥

អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នថវិកាកម្មវិធី
- គ្រប់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត
- ដូចប្រការ១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ